Restoration CHRISTIAN MINISTRY PATHWAYS to WHOLENESS

**Prayer**

## ការអធិស្ឋាន

Prayer is conversation with our Father, God Almighty. We pray to the Father in the name of Jesus, approaching God under the authority of Jesus and, by His permission. We come before God's throne of grace, not in our own merit, but in the merit of Jesus.

ការអធិស្ឋាន គឺជាការសន្ទនាជាមួយព្រះបិតា ដ៏ជាព្រះពេញដោយព្រះចេស្ដារបស់យើង។ យើងអធិស្ឋានទៅកាន់ព្រះបិតា នៅក្នុងព្រះនាមរបស់ព្រះយេស៊ូវ ចូលទៅរកព្រះជាម្ចាស់ ដោយនៅក្រោមសិទ្ធិអំណាចរបស់ព្រះយេស៊ូវ និងដោយមានការអនុញ្ញាតរបស់ទ្រង់។ យើងចូលទៅមុខបល្ល័ង្កនៃព្រះគុណរបស់ព្រះ មិនមែនដោយការប្រព្រឹត្ត (បុណ្យ) របស់យើងឡើយ ប៉ុន្តែ ដោយការប្រព្រឹត្ត (បុណ្យ) របស់ព្រះយេស៊ូវវិញ។

**Cleansing our self**

## ការលាងជម្រះខ្លួនរបស់យើង

Before I read the Word, pray, leave anyplace (sometime in the parking lot and always as soon as I get in my car), after opening an email or text, watching television, returning from work, after a phone call, shopping or a restaurant, etc.; I pray cleansing over myself.

មុនពេលខ្ញុំចាប់ផ្ដើមអានព្រះបន្ទូល អធិស្ឋាន ចាកចេញពីកន្លែងណាមួយ (ពេលខ្លះនៅចំណតឡាន ហើយគ្រប់ពេលដែលខ្ញុំចូលក្នុងឡានរបស់ខ្ញុំ) ក្រោយពេលបើកអ៊ីម៉ែល ឬសារ ការមើលទូរទស្សន៍ ការត្រឡប់មកពីធ្វើការ ក្រោយការតេទូរស័ព្ទ ការដើរផ្សារ ឬចូលភោជនីយដ្ឋាន ជាដើម ខ្ញុំតែងតែអធិស្ឋានសុំការលាងជម្រះលើខ្លួនខ្ញុំ។

The Bible tells us in **Ephesian 6:12** *"For we do not wrestle against flesh and blood, but against principalities, against powers, against the rulers of the darkness of this age, against spiritual hosts of wickedness in the heavenly places."* These principalities, powers, rulers of darkness and spiritual hosts of wickedness are everywhere; and they want to get into your space!

ព្រះគម្ពីរប្រាប់យើងនៅក្នុង**អេភេសូរ ៦:១២** ថា *"ដ្បិតយើងរាល់គ្នាមិនមែនតយុទ្ធនឹងសាច់ឈាមទេ គឺនឹងពួកគ្រប់គ្រង ពួកមានអំណាច និងពួកម្ចាស់នៃសេចក្ដីងងឹតនៅលោកីយ៍នេះវិញ ហើយទាស់នឹងអំណាចអាក្រក់ខាងវិញ្ញាណនៅស្ថានដ៏ខ្ពស់ដែរ។"* ពួកគ្រប់គ្រង ពួកមានអំណាច ពួកម្ចាស់នៃសេចក្ដីងងឹត និងអំណាចអាក្រក់ខាងវិញ្ញាណមាននៅគ្រប់ទីកន្លែង។ ហើយពួកវាចង់ចូលទៅក្នុងជីវិតរបស់អ្នក!

I tell the story of a person who was the head of a vegetarian organization. She had a business meeting one day and her client wanted to meet at the local smoked BBQ restaurant. After her meeting with the client, she went to her scheduled monthly vegetarian organization meeting. When she walked in, everyone she passed by could smell the smoked BBQ on

her. Even though she did not eat the BBQ, the “residue” of the smoke was all over her. Like the smell from the BBQ that followed her around the rest of the day; the “residue” of spiritual hosts of wickedness, which are everywhere, follow us. My habit is to cleanse myself and my space all day anytime my atmosphere changes.

ខ្ញុំសូមប្រាប់អំពីរឿងមនុស្សម្នាក់ដែលជាប្រធានអង្គការអ្នកញ៉ាំអាហារបួសមួយ។ នាងមានកិច្ចប្រជុំធុរកិច្ចមួយនៅថ្ងៃមួយ ហើយអតិថិជនរបស់នាងចង់ជួបនាងនៅក្នុងភោជនីយដ្ឋានបាប៊ីឃ្យូមួយកន្លែង។ ក្រោយកិច្ចប្រជុំជាមួយអតិថិជន នាងបានចូលរួមកិច្ចប្រជុំប្រចាំខែនៅអង្គការអ្នកញ៉ាំអាហារបួសរបស់នាង។ ពេលដែលនាងដើរចូល មនុស្សគ្រប់គ្នាដែលនាងដើរកាត់ អាចធុំក្លិនផ្សែងបាប៊ីឃ្យូនៅលើខ្លួននាង។ ទោះបីជានាងមិនបានទទួលទានសាច់អាំងនោះក៏ដោយ ប៉ុន្តែ “សំណល់” នៃផ្សែងមានពេញលើខ្លួនរបស់នាង។ ដូចជាក្លិនចេញពីសាច់អាំងដែលតាមជាប់នាងពេញមួយថ្ងៃ នោះ “សំណល់” នៃអំណាចអាក្រក់ខាងវិញ្ញាណដែលមាននៅគ្រប់ទីកន្លែងក៏មកតាមយើងផងដែរ។ ខ្ញុំមានទម្លាប់លាងជម្រះខ្លួន និងកន្លែងរបស់ខ្ញុំ គ្រប់ពេលដែលបរិយាកាសរបស់ខ្ញុំផ្លាស់ប្តូរ។

**A Prayer of Cleansing**

**ការអធិស្ឋានលាងជម្រះ**

**“Heavenly Father, I come before You in the name of Jesus. I apply the blood of Jesus over and around me. In the authority I have in the name of Jesus – I command any and all evil spirits and every demonic force that would try to attach to me or the space that I am in; to go now to the dry place of Jesus’ choosing. Your assignment is broken in the name of Jesus!!!”**

**“ឱ ព្រះបិតាដែលគង់នៅស្ថានសួគ៌ ទូលបង្គំសូមចូលមកចំពោះទ្រង់នៅក្នុងព្រះនាមរបស់ព្រះយេស៊ូវ។ ទូលបង្គំសូមលាបព្រះលោហិតរបស់ព្រះយេស៊ូវនៅលើ និងជុំវិញខ្លួនរបស់ទូលបង្គំ។ នៅក្នុងសិទ្ធិអំណាចដែលទូលបង្គំមាននៅក្នុងព្រះនាមព្រះយេស៊ូវ ទូលបង្គំបញ្ជាទៅកាន់គ្រប់ពួកវិញ្ញាណអាក្រក់ និងពួកបរិវាររបស់វា ដែលព្យាយាមចាប់ទូលបង្គំ ឬកន្លែងដែលទូលបង្គំស្ថិតនៅ ឲ្យចេញទៅឥឡូវនេះ ទៅកាន់ទីហួតហែងតាមការជ្រើសរើសរបស់ព្រះយេស៊ូវ! ដ្បិតកិច្ចការរបស់ឯងត្រូវបានបំផ្លាញរួចហើយ នៅក្នុងព្រះនាមព្រះយេស៊ូវ!**

**The Word of God**

**ព្រះបន្ទូលរបស់ព្រះ**

If possible, when studying, meditating and contemplating (thinking deeply and carefully on) God’s Word; read it aloud and in private, with no interruptions. Guard this devotional time, for it is a precious time between your Creator and you! Always enter into God’s Presence with your heart filled with praise & worship unto Him!

បើអាច ពេលដែលអ្នកសិក្សា សញ្ជឹងគិត និងពិចារណាយ៉ាងយកចិត្តទុកដាក់ទៅលើព្រះបន្ទូលរបស់ព្រះ សូមអានឲ្យខ្លាំងៗ និងនៅកន្លែងស្ងប់ស្ងាត់ ដោយគ្មានសេចក្តីរំខាន។ ចូរការពារពេលរបស់អ្នកជាមួយព្រះនេះ ដ្បិតវាជាពេលដ៏មានតម្លៃបំផុតរវាងព្រះអាទិកររបស់អ្នក ហើយនិងអ្នក! តែងតែចូលទៅក្នុងព្រះវត្តមានរបស់ព្រះ ទាំងដួងចិត្តពេញដោយការសរសើរ និងការថ្វាយបង្គំចំពោះទ្រង់ជានិច្ច!

- Ask Father God to open your eyes, ears and heart to His Word to give you understanding: **Ephesians 1:17-23** “that the God of our Lord Jesus Christ, the Father of glory, may give to you the spirit of wisdom and revelation in the knowledge of Him, [18] the eyes of your understanding being enlightened; that you

may know what is the hope of His calling, what are the riches of the glory of His inheritance in the saints, [19] and what *is* the exceeding greatness of His power toward us who believe, according to the working of His mighty power [20] which He worked in Christ when He raised Him from the dead and seated *Him* at His right hand in the heavenly *places,* [21] far above all principality and power and might and dominion, and every name that is named, not only in this age but also in that which is to come.[22] And He put all *things* under His feet, and gave Him *to be* head over all *things* to the church, [23] which is His body, the fullness of Him who fills all in all."

- ចូរទូលសុំឲ្យព្រះបិតាបើកភ្នែក បើកត្រចៀក និងដួងចិត្តរបស់អ្នកឲ្យមើលឃើញ និងស្តាប់ឮព្រះបន្ទូលរបស់ទ្រង់ ដើម្បីឲ្យទ្រង់ប្រទានការយល់ដឹងដល់អ្នក៖ **អេភេសូរ ១:១៧-២៣៖** "[17]ដើម្បីនឹងសូមឲ្យព្រះនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង គឺជាព្រះវរបិតាដ៏មានសិរីល្អ បានប្រទានឲ្យអ្នករាល់គ្នាបានព្រះវិញ្ញាណ ដែលប្រោសឲ្យមានប្រាជ្ញា ហើយក៏បើកសម្តែងឲ្យដឹងពីដំណើរស្គាល់ទ្រង់ [18]ដើម្បីឲ្យភ្នែកចិត្តរបស់អ្នករាល់គ្នាបានភ្លឺឡើង ប្រយោជន៍ឲ្យបានដឹងថា ដែលទ្រង់ហៅអ្នករាល់គ្នា នោះមានសេចក្តីសង្ឃឹមជាយ៉ាងណា ហើយថា សិរីល្អដ៏ប្រសើរក្រៃលែងនៃមរដកទ្រង់ ក្នុងពួកបរិសុទ្ធជាយ៉ាងណាផង [19]ហើយថាព្រះចេស្តាដ៏ខ្លាំងលើសលន់របស់ទ្រង់ ដល់យើងរាល់គ្នាដែលជឿជាយ៉ាងណាដែរ តាមដែលកម្លាំងទ្រង់ដ៏មានឫទ្ធិបានពូកែនឹងធ្វើ [20]ជាព្រះចេស្តាដែលទ្រង់បានសម្តែងចេញ ដោយប្រោសព្រះគ្រីស្ទ ឲ្យមានព្រះជន្មរស់ពីស្លាប់ឡើងវិញ ព្រមទាំងតាំងឲ្យគង់ខាងស្តាំទ្រង់ *នៅស្ថាន*ដ៏ខ្ពស់ [21]ឲ្យខ្ពស់ជាងអស់ទាំងពួកគ្រប់គ្រង ពួកមានអំណាច មានឫទ្ធិបារមី និងពួកមេទាំងប៉ុន្មាន ហើយគ្រប់ទាំងឈ្មោះដែលបានតាំងឡើងដែរ មិនមែនតែក្នុងបច្ចុប្បន្ននេះតែប៉ុណ្ណោះ គឺទៅក្នុងអនាគតខាងមុខទៀតផង [22]ហើយទ្រង់បានបង្ក្រាបគ្រប់ទាំងអស់ នៅក្រោមព្រះបាទនៃព្រះរាជបុត្រា ទាំងប្រទានទ្រង់មកធ្វើជាសិរសាលើគ្រប់ទាំងអស់ ដល់ពួកជំនុំ ដែលជារូបកាយទ្រង់ [23]គឺជាសេចក្តីពោរពេញរបស់ព្រះអង្គ ដែលបំពេញគ្រប់ទាំងអស់ ក្នុងទាំងអស់។"
- Know that God's Word will accomplish what God pleases: **Isaiah 55:10-11** "For as the rain comes down, and the snow from heaven, and do not return there, but water the earth, and make it bring forth and bud, that it may give seed to the sower and bread to the eater, so shall My Word be that goes forth from My Mouth; it shall not return to Me void, but it shall accomplish what I please, and it shall prosper *in the thing* for which I sent it."
- ត្រូវដឹងថា ព្រះបន្ទូលរបស់ព្រះនឹងសម្រេចតាមអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ៖ **អេសាយ ៥៥:១០-១១៖** "[10]ពីព្រោះដែលភ្លៀង និងហិមៈធ្លាក់ចុះមកពីលើមេឃឥតវិលត្រឡប់ទៅលើវិញ គឺមកស្រោចដីធ្វើឲ្យកើតចេញជាពន្លកឡើង ហើយក៏ឲ្យពូជពង្រោះដល់អ្នកដែលព្រោះ និងអាហារដល់អ្នកដែលបរិភោគជាយ៉ាងណា [11]នោះពាក្យអញដែលចេញពីមាត់អញទៅ ក៏មិនដែលវិលមកឯអញវិញ ដោយឥតកើតផលយ៉ាងដូច្នោះដែរ គឺនឹងធ្វើសម្រេចតាមសេចក្តីប៉ងប្រាថ្នានៅក្នុងចិត្តអញ ហើយនិងចម្រើនកើនឡើង ក្នុងការអ្វីដែលអញចាត់ទៅធ្វើនោះ។"
- If possible, set a quiet special place to be alone with God: **Matthew 6:6** "But you, when you pray, go into your room, and when you have shut your door, pray to your Father who *is* in the secret *place;* and your Father who sees in secret will reward you openly."

- បើអាច ចូររកកន្លែងដ៏ស្ងប់ស្ងាត់ពិសេសមួយ ដើម្បីចំណាយពេលតែម្នាក់ឯងជាមួយព្រះ៖ **ម៉ាថាយ ៦:៦៖** "តែឯអ្នក កាលណាអធិស្ឋាន នោះត្រូវឲ្យចូលទៅក្នុងបន្ទប់ ហើយបិទទ្វារ រួចអធិស្ឋានដល់ព្រះវរបិតានៃអ្នក ដែលទ្រង់គង់នៅទីលាក់កំបាំងចុះ នោះព្រះវរបិតានៃអ្នក ដែលទតឃើញក្នុងទីលាក់កំបាំង ទ្រង់នឹងប្រទានរង្វាន់ដល់អ្នកនៅទីប្រចក្សច្បាស់។"
- God's Word is eternal: **Mark 13:31** "Heaven and earth will pass away, but My Words will by no means pass away."
- ព្រះបន្ទូលរបស់ព្រះស្ថិតនៅអស់កល្បជានិច្ច។ **ម៉ាកុស ១៣:៣១៖** "ផ្ទៃមេឃ ហើយផែនដីនឹងកន្លងបាត់ទៅ តែពាក្យខ្ញុំ នឹងមិនដែលកន្លងបាត់ឡើយ។"
- God, the Holy Spirit, is our helper and teacher: **John 14:26** "But the Helper, the Holy Spirit, whom the Father will send in My Name. He will teach you all things, and bring to your remembrance all things that I said to you."
- ព្រះវិញ្ញាណបរិសុទ្ធ គឺជាជំនួយ និងជាគ្រូរបស់យើង។ **យ៉ូហាន ១៤:២៦៖** "តែព្រះដ៏ជាជំនួយ គឺជាព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះវរបិតានឹងចាត់មក ដោយនូវឈ្មោះខ្ញុំ ទ្រង់នឹងបង្រៀនអ្នករាល់គ្នា ពីគ្រប់សេចក្តីទាំងអស់ ក៏នឹងរំឭកពីគ្រប់ទាំងសេចក្តីដែលខ្ញុំបានប្រាប់ដល់អ្នករាល់គ្នាដែរ។"
- God's Promises are yes and amen: **II Corinthians 1:20** "For all the promises of God in Him *are* Yes, and in Him Amen, to the glory of God through us."
- ព្រះបន្ទូលសន្យារបស់ព្រះសុទ្ធតែជា "បាទ" និង "អាម៉ែន"។ **២កូរិនថូស ១:២០៖** "ដ្បិតទោះបើមានសេចក្តីសន្យារបស់ព្រះយ៉ាងណាក៏ដោយ ក៏នៅសុទ្ធតែជា «បាទ» ក្នុងទ្រង់ ហើយ «អាម៉ែន» ក្នុងទ្រង់ដែរ សម្រាប់នឹងចម្រើនសិរីល្អដល់ព្រះ ដោយសារយើងរាល់គ្នា។"
- The Word of God has been given to us to study and meditate on. **II Timothy 3:16** "All Scripture *is* given by inspiration of God, and *is* profitable for doctrine, for reproof, for correction, for instruction in righteousness."
- ព្រះបន្ទូលរបស់ព្រះត្រូវបានប្រទានមក ដើម្បីឲ្យយើងសិក្សា និងសញ្ជឹងគិត។ **២ធីម៉ូថេ ៣:១៦៖** "គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឲ្យតែងទេ ក៏មានប្រយោជន៍សម្រាប់ការបង្រៀន ការរំឭកឲ្យដឹងខ្លួន ការប្រដៅតម្រង់ និងការបង្ហាត់ខាងឯសេចក្តីសុចរិត។
- God's Word will endure forever and ever: **I Peter 1:25** "But the word of the Lord endures forever.  Now this is the word which by the gospel was preached to you."
- ព្រះបន្ទូលរបស់ព្រះនឹងនៅស្ថិតស្ថេរអស់កល្បជានិច្ច។ **១ពេត្រុស ១:២៥៖** "តែឯព្រះបន្ទូលនៃព្រះអម្ចាស់ នោះនៅជាប់អស់កល្បជានិច្ចវិញ គឺជាព្រះបន្ទូលនេះ ដែលបានផ្សាយមកអ្នករាល់គ្នាហើយ។"

**A Prayer before going to the Word of God**
**ការអធិស្ឋាន មុនពេលចូលទៅរកព្រះបន្ទូលនៃព្រះ**

**"Heavenly Father, I come before You in the name of Jesus and thank You for this day! This is the day that You have made and I am rejoicing and glad in it!  And Father, as**

**I prepare now to read or listen to Your Word, I ask You to enlighten my understanding. Give me ears to hear, eyes to see and a heart to receive.  Amen.”**

«ឱ ព្រះបិតាដែលគង់នៅស្ថានសួគ៌ ទូលបង្គំសូមចូលទៅរកទ្រង់ នៅក្នុងព្រះនាមព្រះយេស៊ូវ និងសូមអរព្រះគុណទ្រង់សម្រាប់ថ្ងៃនេះ! នេះជាថ្ងៃដែលទ្រង់បានបង្កើត ហើយទូលបង្គំនឹងរីករាយ ហើយសប្បាយនឹងវា! ឱ ព្រះបិតាអើយ ពេលដែលទូលបង្គំរៀបនឹងអាន ឬស្ដាប់ព្រះបន្ទូលរបស់ទ្រង់ ទូលបង្គំសុំឲ្យទ្រង់ជួយបំភ្លឺដល់ការយល់ដឹងរបស់ទូលបង្គំផង។ សូមប្រទានឲ្យទូលបង្គំមានត្រចៀកដែលស្ដាប់ឮ ភ្នែកដែលមើលឃើញ និងដួងចិត្តដែលចាំទទួល។ អាម៉ែន។»

**Pastor Ron Schoenherr**
restorationchristianministry@gmail.com
www.rcministry.org

All scripture references are taken from the **New King James Version**, Thomas Nelson, Inc.
គ្រប់បទគម្ពីរយោងទាំងអស់ត្រូវបានដកស្រង់ចេញពី**ព្រះគម្ពីរបរិសុទ្ធ**។